ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ







# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ
## ២០០៩-២០១១



## ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង


រៀបចំដោយៈ

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ស៊ីធរកណ្តាល

សហការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី



មិថុនា ២០០៩

# មាតិកា


**អារម្ភកថា** ---------------------------------------- iii

**ក្រុមការងារ** ----------------------------------------iv

**១. សេចក្តីផ្តើម** ----------------------------------------១

១.១-ប្រវត្តិគ្រោះទឹកជំនន់នៅកម្ពុជា ----------------------------------------១

១.២-ការរៀបចំផែនការ និង សារៈសំខាន់ ----------------------------------------៥

ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់? ----------------------------------------៥

ខ. តើចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ? ----------------------------------------៥

គ. អ្នកណាជាអ្នករៀបចំផែនការ? ----------------------------------------៦

ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច? ----------------------------------------៦

ង. តើផែនការនេះសម្រាប់អ្នកណា? ----------------------------------------៦

១.៣-ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព ----------------------------------------៧

**២. ទិន្នន័យទូទៅរបស់ស្រុក** ----------------------------------------៧

២.១-ទីតាំងភូមិសាស្ត្រ និងទំហំផ្ទៃដី ----------------------------------------៧

ក. ទីតាំងភូមិសាស្ត្រ ----------------------------------------៧

ខ. ចំនួនឃុំ ភូមិ និង ចំនួនគ្រួសារ ----------------------------------------៧

គ. ចំនួនផ្ទៃដីនិងប្រភេទដី----------------------------------------៨

២.២-ទិន្នន័យប្រជាសាស្ត្រ ----------------------------------------៩

ក. ចំនួនប្រជាពលរដ្ឋ ----------------------------------------៩

ខ. មុខរបរសំខាន់របស់ប្រជាជន----------------------------------------៩

គ. កម្រិតវប្បធម៌ ---------------------------------------- ១០

ឃ. សេដ្ឋកិច្ច ---------------------------------------- ១០

២.៣-ប្រវត្តិគ្រោះមហន្តរាយ ---------------------------------------- ១១

ក. ការវិភាគលើមុខសញ្ញាបង្កគ្រោះថ្នាក់នានាពីឆ្នាំ ២០០២-២០០៨---------------------------------------- ១១

ខ. ការវិភាគភាពងាយរងគ្រោះ ---------------------------------------- ១២

គ. ផែនទីគ្រោះមហន្តរាយទឹកជំនន់ ឆ្នាំ២០០០របស់ស្រុកស៊ីធរកណ្តាល ---------------------------------------- ១៣

២.៤-ធនធានសំខាន់ៗ ---------------------------------------------------- ១៤

ក. សាលារៀននៅឆ្នាំ២០០៨------------------------------------------------- ១៤

ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ------------------------------------------- ១៤

គ. ទីទួលសុវត្ថិភាព និង ទីតាំង ---------------------------------------------- ១៥

ឃ. មធ្យោបាយដឹកជញ្ជូន---------------------------------------------------- ១៥

ង. ប្រព័ន្ធធារាសាស្រ្ត------------------------------------------------------ ១៥

ច. ប្រព័ន្ធទំនាក់ទំនង ------------------------------------------------------ ១៦

៣. ផែនការសកម្មភាពជាតិនៃយុទ្ធសាស្រ្តសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ -------------- ១៧

៣.១-ក្របខណ្ឌការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ---------------------------- ១៧

៣.២-តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ----------------------១៩

**៤. យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ** ----------------------------------------២០

៤.១-សមាសភាព--------------------------------------------------------------២០

៤.២-តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក -----------------២០

៤.៣-រចនាសម្ព័ន្ធគណៈកម្មាធិកាគ្រប់គ្រងគ្រោះមហន្តរាយស្រុក -------------------------------- ២២

៤.៤-ក្រុមប្រតិបត្តិការ-------------------------------------------------------- ២៣

**៥. ផែនការសកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់របស់ការិយាល័យ-អង្គភាពជុំវិញស្រុកស៊ីធរកណ្តាលសំរាប់ អនុវត្តឆ្នាំ: ២០០៩-២០១១** ---------------------------------------------------- ២៦

**ឧបសម្ពន្ធ័**

១. ដីការបង្កើត និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

២. បញ្ជីឈ្មោះអង្គការជាតិ-អន្តរជាតិនានាក្នុងខេត្តព្រៃវែង

៣. ផែនទីស្រុកស៊ីធរកណ្តាល

# អារម្ភកថា

ក្រោមការជួយគាំទ្របច្ចេកទេសពី គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត(PCDM) និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM) និងមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) ដោយមានការជួយឧបត្ថម្ភថវិកាពីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសប្រទេសអាឡឺម៉ង់ (GTZ) តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ (MRCs) ដោយមានការសម្របសម្រួលពីគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាលបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ស្រុករបស់ខ្លួន ដែលបានរៀបចំឡើងតាំងពីឆ្នាំ២០០៧មកនោះ ឱ្យកាន់តែមានលក្ខណៈស៊ីជម្រៅ និងច្បាស់លាស់ថែមទៀត ពិសេសបានកែសម្រួលពីផែនការដែលមានលក្ខណៈរួម មកជាផែនការសកម្មភាពអាទិភាពតាមការិយាល័យជុំវិញស្រុកវិញ សម្រាប់អនុវត្តរយៈពេលបីឆ្នាំ គឺចាប់ពីឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១១។

ផែនការនេះ ជាផែនការមេ សម្រាប់អនុវត្តលើកម្មវិធីគ្រប់គ្រងគ្រោះទឹកជំនន់ថ្នាក់ស្រុក ដែលចែកចេញជា បីដំណាក់កាលសំខាន់ៗ (១).ដំណាក់កាលត្រៀមបង្ការមុនពេលទឹកជំនន់ (២).ដំណាក់កាលឆ្លើយតបក្នុងពេលទឹកជំនន់ និង (៣). ដំណាក់កាលស្តារនិងជួសជុលឡើងវិញក្រោយពេលទឹកជំនន់។ ការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះមានការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំស្រុក ការិយាល័យ និងអង្គភាពជុំវិញស្រុក ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល និងមានការចូលរួមពីបណ្តាអង្គការជាតិ-អន្តរជាតិ ដែលបាននឹងកំពុងប្រតិបត្តិការការងារនៅក្នុងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ផងដែរ។

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះជាយុទ្ធសាស្ត្រមួយរបស់ស្រុក សំដៅធានាដល់ការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់មកលើវិស័យសេដ្ឋកិច្ច សុខមាលភាពរបស់ប្រជាពលរដ្ឋ-សត្វ ហេដ្ឋារចនាសម្ព័ន្ធជាតិ និងជនបទរបស់ស្រុកឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍរបស់ខេត្ត និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល សូមកោតសសើរដោយស្មោះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្ត-រាយ និងមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើផែនការនេះឱ្យកើតចេញជារូបរាងឡើងកាន់តែមានលក្ខណៈពេលលេញ។ លើសពីនេះទៀត ក៏សូមថ្លែងអំណរគុណចំពោះ ភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសប្រទេសអាឡឺម៉ង់ ដែលបានផ្តល់ថវិកាគាំទ្រដល់ការរៀបចំផែនការនេះតាំងពីជំហានទី១ ក៏ដូចជាការកែសម្រួលក្នុងជំហានទី២នេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាល ជ្រៅចំពោះ

ការិយាល័យ-អង្គភាពជុំវិញស្រុក ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល ព្រមទាំង អង្គការជាតិ-អន្តរជាតិនានាក្នុងស្រុក ដែលបានចូលរួមយ៉ាង សកម្មក្នុងដំណើរការរៀបចំផែនការនេះឡើង។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកសីធរកណ្តាលមានជំនឿយ៉ាងមុតមាំថា នឹងអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់សម្រាប់រយៈពេលបីឆ្នាំ(២០០៩-២០១១)នេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ស៊ីធរកណ្តាល , ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក**

**កេ_អ៊ឹម**

# ក្រុមការងារ

កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ត្រូវបានកែសម្រួលនិងធ្វើបច្ចុប្បន្នភាព ដោយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្រោមកិច្ចគាំទ្របច្ចេកទេសពី គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត(PCDM) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM) និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) ដូចមានសមាសភាពខាងក្រោម :

- **សមាសភាពក្រុមការងារ:**

១ . លោក សុទ្ធ គឹមកុលមុនី មន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២. លោក ហ៊ុល ចំរើន លេខាធិការរង នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង

៣. លោក ពា គឹមយាង អភិបាលរងទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយស្រុក

៤. លោក អុល សែន មន្ត្រីសម្របសម្រួលកម្មវិធី នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

- **ពិនិត្យតាមដាន និងផ្តល់បច្ចេកទេស:**

១. ឯ.ឧ. ប៊ុន ណារិទ្ធិ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២. លោក អ៊ុំ ប៊ុនឡេង នាយខុទ្ទកាលយសាលាខេត្តព្រៃវែង និងជាលេខាធិការអចិន្ត្រៃយ៍នៃ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយខេត្ត

៣.លោក ភេ អ៊ឹម អភិបាលស្រុកស៊ីធរកណ្តាល

៤. លោក ជុំ វុទ្ធី ប្រធានគម្រោងថ្នាក់ជាតិ នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**ស្ថាប័នដែលបានចូលរួមចំណែក:**

- ការិយាល័យ និង អង្គភាព ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល
- តំណាងអង្គការជាតិ-អន្តរជាតិ ក្នុងស្រុកស៊ីធរកណ្តាល

# ផែនការត្រៀមបង្ការគ្រោះមហន្តរាយ
# ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

## ១. សេចក្តីផ្តើម

### ១.១.ប្រវត្តិគ្រោះទឹកជំនន់នៅកម្ពុជា

ទន្លេមេគង្គ ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា ។ ទន្លេមេគង្គ និង ដៃរបស់វា និង ទឹកភ្លៀងដ៏ច្រើនលើសលប់ ជាហេតុធ្វើឱ្យមានទឹកជំនន់ប្រចាំឆ្នាំ ប៉ះពាល់មកលើតំបន់ដែលមានផ្ទៃក្រលា ប្រហែល ១៧.១០០ គីឡូម៉ែត្រ ឬ ស្មើនឹង ២៥ ភាគរយនៃផ្ទៃដីទំនាបនៃអាងទន្លេមេគង្គ។ ភ្លៀងធ្លាក់ខ្លាំង នៅរដូវវស្សា និង ការកាប់បំផ្លាញព្រៃឈើ បានធ្វើឱ្យមានទឹកជំនន់ លឿន។ ជាញឹកញាប់លំហូរទឹកទន្លេមេគង្គមានភាពខ្ពស់ជាងច្រាំងទន្លេ ដោយសារតែមានភ្លៀងធ្លាក់ខ្លាំងមានទឹកហូរមកចាក់ ក្នុងអាងទន្លេបានធ្វើឱ្យមានទឹកជំនន់នៅតាមបណ្តាខេត្តដែលមានទីតាំងនៅតាមតំបន់ទំនាប ។ តំបន់ប្រឈមមុខនឹងគ្រោះទឹក ជំនន់នៅជុំវិញភ្នំពេញ និង តំបន់មួយភាគធំចុះទៅព្រំដែនប្រទេសវៀតណាម មានផ្ទៃដីប្រមាណ ៧.០០០ គីឡូម៉ែត្រក្រលា។ខេត្ត ដែលប្រឈមមុខនឹងគ្រោះទឹកជំនន់ទន្លេមេគង្គរួមមាន ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្តាល ព្រៃវែង និង ស្វាយរៀង ។

ទឹកជំនន់នៅឆ្នាំ ២០០០ ត្រូវបានគេរាយការណ៍ថា មានសភាពធ្ងន់ធ្ងរជាងគេ នៅក្នុងរយៈពេលជាង ៧០ ឆ្នាំ ។ របាយការណ៍ផ្លូវការនេះ រៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ បានឱ្យដឹងថា មានមនុស្សស្លាប់ចំនួន ៣៤៧ នាក់ (ក្នុងនោះ ៨០ ភាគរយ ជាកុមារ ) ប្រជាជនចំនួន ៧៥០.៦១៨ គ្រួសារស្មើនឹងមនុស្សចំនួន ៣.៤៤៨.៦២៩ នាក់ នៅក្នុង ២១ ខេត្ត និងក្រុងបានទទួលរងការ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយទឹកជំនន់ ក្នុងនោះប្រជាជនចំនួន ៨៥.០០០ គ្រួសារស្មើនឹង មនុស្សចំនួន ៣៨៧.០០០ នាក់ បានជម្លៀសទៅស្នាក់នៅបណ្តោះអាសន្ននៅលើទីទួលសុវត្ថិភាព ។ លើសពីនោះទៀត ផ្ទះចំនួន ៣១៧ ៩៧៥ ខ្នងទទួលរងការប៉ះពាល់ ក្នុងនោះ ៧.០៦៨ ខ្នងត្រូវខូចខាតទាំងស្រុង ។ ដំណាំកសិកម្ម និង ដំណាំផ្សេង ៗ ទៀតចំនួន ៦៨៨.០២១ ហិចតា ត្រូវទទួលរងការប៉ះពាល់ និង ខូចខាត។ ផ្អែកតាមរបាយការណ៍របស់គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ គណៈរដ្ឋមន្ត្រីបានប៉ាន់ស្មាន និង វាយតម្លៃពីផលប៉ះពាល់ និង ការខូចខាតសរុបអស់ប្រ ហែល ១៥៧ លានដុល្លារ អាមេរិក ។ នៅឆ្នាំ ២០០១ ផលប៉ះពាល់ដោយទឹកជំនន់នៅក្នុងប្រទេសកម្ពុជា ត្រូវបាន គេវាយតម្លៃថាអស់ប្រហែល ៣៦ លានដុល្លារអាមេរិក និង ទឹកជំនន់ ឆ្នាំ ២០០២ មានប្រជាជនចំនួនប្រហែល ១លានកន្លះ និង ផ្ទៃដីកសិកម្មចំនួន ៦.០០០ហិចតា ត្រូវបានទទួល ការប៉ះពាល់ ។

ស្ថិតិ និង ទិន្នន័យសង្ខេប ពីផលប៉ះពាល់ទឹកជំនន់ឆ្នាំ ២០០០ :

- ផ្ទះទទួលរងការប៉ះពាល់ចំនួន ៣១៧.៤០០ ខូចខាតចំនួន ៧.០០០ ខ្នង
- **ផ្នែកអប់រំ សិក្សាធិការ** : សាលារៀនទទួលការខូចខាតចំនួន ៩៨៨ ខ្នង

- **ផ្នែកសុខភាព** : មណ្ឌលសុខភាពខូចខាតចំនួន ១៣៨ ខ្នង
- **ផ្នែកកសិកម្ម** : - ស្រូវទទួលរងការខូចខាត ចំនួន ៣៧៤.០០០ ហិចតា
  - ដំណាំផ្សេង ៗទទួលរងការខូចខាតចំនួន ៤៧.០០០ ហិចតា
  - សត្វពាហនៈ ស្លាប់ចំនួន ៣.៩០០ ក្បាល
- **ផ្នែកហេដ្ឋារចនាសម្ព័ន្ធ** :
  - ផ្លូវជាតិ និង ផ្លូវខេត្តទទួលការខូចខាតប្រវែង ២.៦០០ គីឡូម៉ែត្រ
  - ផ្លូវរថភ្លើង ១១៥ គីឡូម៉ែត្រ
  - ស្ពាន ១១៥ កន្លែង
  - អណ្ដូងទឹក និង លូទឹក ១១.៩០០
  - ប្រព័ន្ធធារាសាស្ត្រ ១១៣ ម៉ែត្រ

គេទទួលស្គាល់ថា នៅក្នុងអាងទន្លេមេគង្គ ទឹកជំនន់បានកើតឡើងផ្ទួនៗ បានធ្វើឱ្យសំបូរត្រី និងជីវៈចម្រុះ នៅក្នុងតំបន់ អាចផ្តល់ទឹក ផ្លូវនាវាចរ និង ធ្វើឱ្យដីកសិកម្មមានជីជាតិ ដែលទាក់ទងនឹងតំបន់ដីសើមនៅតាមទំនាប ជាប្រភពសំខាន់សម្រាប់ ជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់សម្រាប់ប្រកបរបរចិញ្ចឹមជីវិតនៅតាមតំបន់ដីសើមនេះ ។

ទន្ទឹមគ្នានេះ ទឹកជំនន់ទន្លេមេគង្គបានបង្កឱ្យមានការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និង រំខានដល់សកម្មភាពអភិវឌ្ឍន៍សង្គម និងការបង្កបង្កើតផលរបស់ប្រជាជននៅតាមតំបន់អាងទន្លេមេគង្គនេះផងដែរ។ ដូច្នេះសកម្មភាព និងវិធានការកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់គួរត្រូវបានរៀបចំធ្វើ ដូចជា ការអន្តរាគមន៍ជាក់ស្តែង ការរៀបចំគោល នយោបាយ និង ការរៀបចំផែនការ ដើម្បីទាញយកផលប្រយោជន៍ពីទឹកជំនន់ ដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាពនៅក្នុងប្រទេស ។ ដូចគ្នានេះដែរ ដើម្បីកាត់បន្ថយផលប៉ះពាល់លើអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន។សកម្មភាព និងវិធានការ ដែលបានធ្វើកន្លងមកទាក់ទងនឹងការងារគ្រប់គ្រងគ្រោះទឹកជំនន់ គឺផ្តោតសំខាន់តែលើការងារ ប្រតិបត្តិការជំនួយសង្គ្រោះបន្ទាន់ តែការងារត្រៀមបង្ការ និងកាត់បន្ថយគ្រោះទឹកជំនន់ ជាការងារចាំបាច់ត្រូវធ្វើ និង យកចិត្តទុកដាក់បំផុត ដូចពាក្យចាស់ លោកថា " ការពារប្រសើរជាងព្យាបាល " ពេលណាដែលទឹកជំនន់បាននាំមក នូវផលប្រយោជន៍ជូនប្រជាជន។ តាមបទពិសោធពីអតីតកាលបានបង្ហាញឱ្យយើងដឹងថា ការចូលរួមយ៉ាងសកម្មពីគ្រប់ មជ្ឈដ្ឋានដែលពាក់ព័ន្ធ និងការចូលរួមជាវិភាគទាន ជាធនធានដែលអាចមាន ដើម្បីធ្វើឱ្យការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមមូលដ្ឋាន អាចជួយឱ្យប្រជាជនដោះស្រាយបានយ៉ាងមានប្រសិទ្ធភាព និង ទាន់ពេលវេលាទៅនឹងគ្រោះទឹកជំនន់តាមរយៈវិធានការនានា។

តាមរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកសីធរកណ្ដាល បានឱ្យដឹងថា តាមបណ្ដា ឆ្នាំខាងលើ ទឹកជំនន់ទន្លេមេគង្គ បានបង្កផលប៉ះពាល់ និងបង្កការខូចខាតលើអាយុជីវិតមនុស្ស សត្វ សេដ្ឋកិច្ចសង្គម ហេដ្ឋា រចនាសម្ព័ន្ធជាច្រើនដូចមាននៅក្នុងរបាយការណ៍សង្ខេប ដូចខាងក្រោម :

- **ផលប៉ះពាល់ឆ្នាំ ២០០០ :**

| | |
|---|---|
| - មនុស្សស្លាប់ចំនួន | ១២ នាក់ |
| - ប្រជាជនរងការប៉ះពាល់ | ១៣.១៤៨ គ្រួសារ ៦៦.៤០៣ នាក់ |
| - ចំនួនឃុំរងការប៉ះពាល់ | ១១ ឃុំ ស្មើ ៥៦ ភូមិ |
| - ចំនួនផ្ទះរងការប៉ះពាល់ | ៧.៥៣១ ខ្នង |
| - ចំនួនផ្ទះរងការខូចខាត | ៣៣ ខ្នង |
| - ស្ពានរងការខូចខាតចំនួន | ៦ កន្លែង |
| - ផ្លូវលំរងការខូចខាតប្រវែង | ៥៨.១៩៧ ម៉ែត្រ |
| - ទំបន់រងការខូចខាតប្រវែង | ១៣.៣០៥ ម៉ែត្រ |
| - ស្រូវវស្សា និង សន្ទូងខូចខាត | ១៦.៩៦៧ ហិកតា |
| - ដំណាំអនុផលខូចខាត | ២៤៨ ហិកតា |
| - សត្វពាហនៈងាប់ | ៩៤ ក្បាល |
| - សាលារៀនរងការខូចខាត | ៣ ខ្នង |

- **ផលប៉ះពាល់ឆ្នាំ ២០០១ :**

| | |
|---|---|
| - មនុស្សស្លាប់ចំនួន | ១១ នាក់ |
| - ប្រជាជនរងការប៉ះពាល់ | ១២.៣០៤ គ្រួសារ ៥២.៨៧៤ នាក់ |
| - ចំនួនឃុំរងការប៉ះពាល់ | ១១ ឃុំ ស្មើ ៥៦ ភូមិ |
| - ចំនួនផ្ទះរងការខូចខាត | ២៣ ខ្នង |
| - ផ្លូវលំរងការខូចខាតប្រវែង | ៣៨.៦៩៨ ម៉ែត្រ |
| - ស្ពានឈើរងការខូចខាតចំនួន | ០៤ ស្ពាន |
| - ទំនប់រងការខូចខាតប្រវែង | ៧.៦៦៣ ម៉ែត្រ |
| - លូរងការខូចខាតចំនួន | ៣១ លូ |
| - អណ្តូងរងការប៉ះពាល់ចំនួន | ២៥៥ |
| - ស្ពានថ្មរងការខូចខាត | ២ កន្លែង |
| - សាលារៀនរងការប៉ះពាល់ | ៣៨ កន្លែង ស្មើ ៧០ ខ្នង |
| - សាលារៀនរងការខូចខាត | ១ ខ្នង |
| - វត្តរងការប៉ះពាល់ចំនួន | ៣៩ លើ ៤៨ វត្ត |
| - របងវិទ្យាល័យព្រែកសណ្តែករងការខូចខាតប្រវែង | ២០ ម៉ែត្រ |

- សត្វពាហនៈងាប់ចំនួន ៤៤ ក្បាល
- សន្ទូងរងការខូចខាតរាំងស្ងួត ១៩៩ ហិកតា
- សន្ទូងរងការខូចខាត ទឹកជំនន់ ១.០៧១ ហិកតា

- **ផលប៉ះពាល់ឆ្នាំ ២០០២ :**

- មនុស្សស្លាប់ចំនួន ០៩ នាក់
- ប្រជាជនរងការប៉ះពាល់ចំនួន ៤៨.០២០ នាក់ ស្មើនិង ៩.៦០៤ គ្រួសារ
- ឃុំរងការប៉ពាល់ចំនួន ១១ ឃុំ ស្មើ ៥៦ ភូមិ
- ផ្ទះរងការប៉ះពាល់ចំនួន ៦.៦៨១ ខ្នង
- ផ្ទះរងការខូចខាតចំនួន ៣៦ ខ្នង
- ស្រូវខូចខាតដោយសារគ្រោះរាំងស្ងួតចំនួន ៥៨៤ ហិកតា
- ស្រូវខូចខាតដោយសារគ្រោះទឹកជំនន់ចំនួន ៧៧៤ ហិកតា
- ដំណាំផ្សេងៗខូចខាតចំនួន ១២៧.១៥ ហិកតា
- សត្វពាហនៈងាប់ចំនួន ៣០ ក្បាល
- អណ្តូងរងការប៉ះពាល់ចំនួន ៨៥០ អណ្តូង
- ផ្លូវលំខូចខាតប្រវែង ២៨.២៥៥ ម៉ែត្រ
- សាលារៀនរងការប៉ះពាល់ចំនួន ៣១ ខ្នង ស្មើនិង ១៤២ បន្ទប់

- **ផលប៉ះពាល់ឆ្នាំ ២០០៣:**

- មនុស្សស្លាប់ចំនួន ០៥ នាក់
- ស្រូវខូចខាតដោយសារគ្រោះរាំងស្ងួតចំនួន ៥២ ហិកតា
- ស្រូវខូចខាតដោយសារទឹកជំនន់ចំនួន ១២៩ ហិកតា
- ខ្យល់ព្យុះដួលផ្ទះចំនួន ១ ខ្នង ( ខូច )

- **ផលប៉ះពាល់ឆ្នាំ ២០០៤:**

- មនុស្សស្លាប់ចំនួន ០៦ នាក់
- ស្រូវខូចខាតដោយសារគ្រោះទឹកជំនន់ចំនួន ៣.៨០៩ ហិកតា
- ខ្យល់ព្យុះបាក់ផ្ទះខូចចំនួន ០២ ខ្នង

- **ផលប៉ះពាល់ឆ្នាំ ២០០៥:**

- មនុស្សស្លាប់ចំនួន ១០ នាក់
- ស្រូវខូចខាតដោយសារគ្រោះទឹកជំនន់ចំនួន ៦.៥៩៩ ហិកតា។

*( ព័ត៌មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ពាមជរ )*

## ១.២_ការរៀបចំផែនការ និង សារៈសំខាន់

### ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ជាវិធានការ ឬសកម្មភាព សម្រាប់អនុវត្តជាមុន ដើម្បីធ្វើឱ្យការឆ្លើយតប និង ស្តារឡើងវិញ ពីផលប៉ះពាល់ដោយគ្រោះទឹកជំនន់បានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ផែនការត្រៀមបង្ការគ្រោះ ទឹកជំនន់មានទិសដៅ និង តួនាទីសំខាន់ៗ ២ ដូចខាងក្រោម :

- វាយតម្លៃធនធាន និង សមត្ថភាពដែលមានស្រាប់នៅគ្រប់ថ្នាក់ រួមមាន ថ្នាក់ស្រុក ឃុំនិង ភូមិ។
- រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការងារត្រៀមបង្ការ ប្រតិបត្តិការឆ្លើយតបសង្គ្រោះ និងស្តារឡើងវិញ ទាំងមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះទឹកជំនន់ ឧទាហរណ៍ ដូចជា ការផ្តល់ព័ត៌មានជាមុនពីគ្រោះថ្នាក់ដែលអាចកើតឡើងឱ្យទាន់ពេលវេលា ការជម្លៀសប្រជាជន និងទ្រព្យ សម្បត្តិ ជាមុនពីកន្លែងគ្រោះថ្នាក់ រៀបចំជម្រកបណ្តោះអាសន្ន ការស្តុកទុកជំនួយសង្គ្រោះ និងការរៀបចំប្រព័ន្ធទំនាក់ទំនង សម្រាប់ប្រើប្រាស់ នៅក្នុងដំណាក់កាល មុនពេល ក្នុងពេល និង ក្រោយពេលមានគ្រោះមហន្តរាយកើតឡើង។

### ខ. តើចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចជួយឱ្យមានការរៀបចំនិងកំណត់ធនធានសម្រាប់ប្រើប្រាស់ក្នុងការកាត់បន្ថយផលប៉ះពាល់គ្រោះមហន្តរាយ។ ការរៀបចំផែនការបានល្អវាអាចជួយយើងនៅក្នុងការងារមួយចំនួន ដូចខាងក្រោម:

- សហគមន៍ងាយរងគ្រោះអាចទទួលបានព័ត៌មានបានទាន់ពេលវេលាដូចជា ព័ត៌មានព្យាករណ៍ និង ព័ត៌មាន ប្រកាសភាពអាសន្នជាដើម
- អាចផ្តល់ឱ្យនូវសេចក្តីត្រូវការចាំបាច់ ដូចជា ជម្រកបណ្តោះអាសន្ន ការថែទាំសុខភាព ទឹកស្អាត និងម្ហូបអាហារ ជូនជនរងគ្រោះ នៅរដូវទឹកជំនន់
- អាចកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជន
- អាចស្តារឡើងវិញបានទាន់ពេលវេលា នូវផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើឱ្យកិច្ចសហការបានល្អ និងមានប្រសិទ្ធភាពក្នុងចំណោមអង្គការនិងស្ថាប័នពាក់ព័ន្ធក្នុងការឆ្លើយតបនៅពេលមានគ្រោះទឹកជំនន់

- អាចធ្វើឱ្យសហគមន៍វិលប្រឡប់ទៅរកស្ថានភាពដើមវិញបានយ៉ាងឆាប់រហ័ស

### គ. អ្នកណាជាអ្នករៀបចំផែនការ?

ផែនការនេះ រៀបចំឡើងដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ការិយាល័យ និង អង្គភាព ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្រោមការគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

ផែនការនេះ ជាផែនការមេ សម្រាប់អនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ដែលអាចធានាធ្វើឱ្យមានការត្រៀមបង្ការ ការឆ្លើយតប និងស្តារឡើងវិញ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព និងសំដៅកាត់បន្ថយ នូវផលប៉ះពាល់ និងខូចខាតលើអាយុជីវិតមនុស្ស-សត្វ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ និង សេដ្ឋកិច្ចសង្គម ដែលបង្កឡើង ដោយគ្រោះមហន្តរាយធម្មជាតិ ជាពិសេសគ្រោះមហន្តរាយទឹកជំនន់។

### ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច?

ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង អ្នកជំនាញការជាតិ និង អន្តរជាតិដែល មានបទពិសោធទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា គណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយស្រុកបាន រៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់របស់ខ្លួន ដែលបាន រៀបចំឡើងតាំងពីឆ្នាំ ២០០៧ ឱ្យកាន់តែមានលក្ខណៈស៊ីជំរៅ និងគ្រប់ជ្រុងជ្រោយជាងមុន តាមរយៈការកែសំរួលលើ ផែនការមានលក្ខណៈរួម ទៅជាផែនការសកម្មភាពដែលមានលក្ខណៈដោយឡែកតាមកម្មវិធីស្នូល របស់ការិយាល័យ/អង្គភាពនីមួយៗជុំវិញស្រុក និង បានអនុម័តជាផ្លូវការនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ ស្រុក។

### ង. តើផែនការនេះសម្រាប់អ្នកណា?

ក្រោយពីបានរៀបចំបានពេញលេញ និងទទួលបានការយល់ព្រមឱ្យប្រើប្រាស់ ពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ឯកសារផែនការនេះនឹងធ្វើការបែងចែក និងផ្សព្វផ្សាយទៅដល់ការិយាល័យ/អង្គភាព ដែលជាសមាជិក គណៈ កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសុក ដើម្បីចាប់ផ្តើមអនុវត្តទៅតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំណត់នៅក្នុងផែនការ ដើម្បីធ្វើឱ្យសម្រេចបានទៅតាមទិសដៅ និងលទ្ធផល ដូចបានកំណត់នៅក្នុងវិធានការ និងសកម្មភាព នីមួយៗ។ ឯកសារផែនការនេះ នឹងដាក់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដើម្បី បញ្ចូលផែនការនេះទៅក្នុង ផែនការរបស់ គណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ និងធ្វើការផ្សព្វផ្សាយផងដែរ ដល់រាជរដ្ឋាភិបាលជាតិ ជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបញ្ចូលផែនការនេះទៅក្នុងផែនការឆ្នាំនៃកម្មវិធីអភិវឌ្ឍន៍ជាតិ-ខេត្ត ស្រុក និង ឃុំ។ លើសពីនេះទៀត ឯកសារផែនការនេះ នឹងធ្វើការ

ផ្សព្វផ្សាយដល់បណ្តាអង្គការជាតិ-អន្តរជាតិពាក់ព័ន្ធទាំងនៅក្នុង និងក្រៅស្រុក ដើម្បីបានទទួលនូវការចូលរួមគាំទ្រទាំងផ្នែកថវិកា និង បច្ចេកទេស សម្រាប់ធានាធ្វើឱ្យផែនការអាចសម្រេចបានលទ្ធផលល្អ និងគោលដៅ ដូចមានចែងក្នុងផែនការនេះ។

### **១.៣. ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព**

| | |
|---|---|
| ក. ស្ថាប័នអនុវត្តផែនការ: | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស៊ីធរកណ្តាល |
| ខ. ផែនការសម្រាប់ឆ្នាំ : | ២០០៩-២០១១ |
| គ. ស្ថាប័នទទួលខុសត្រូវលើការកែសម្រួល និង ធ្វើបច្ចុប្បន្នភាពផែនការ: | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្រោមជំនួយបច្ចេកទេសពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី |
| ឃ. កាលបរិច្ឆេទកែសម្រួលផែនការ: | ខែធ្នូ ឆ្នាំ២០១១ |

## **២. ទិន្នន័យទូទៅរបស់ស្រុក**

### **២.១. ទីតាំងភូមិសាស្ត្រ និងទំហំផ្ទៃដី**

#### **ក. ទីតាំងភូមិសាស្ត្រ**

ស្រុកស៊ីធរកណ្តាល ជាស្រុកមួយស្ថិតនៅភាគខាងជើង នៃទីរួមខេត្តព្រៃវែង និងមានចម្ងាយពីទីរួមខេត្តមកស្រុក ប្រវែង ៥៤ គ.ម ជាប់បណ្តោយផ្លូវជាតិលេខ ១១។ ស្រុកចែកចេញជា ១១ឃុំ មាន ៦០ភូមិ មានព្រំប្រទល់ខាងកើតទល់ ស្រុកកញ្ជ្រៀច និង ស្រុកអូរាំងឪ ខាងលិចទល់ស្រុកពារាំង ខាងជើងទល់ស្រុកកោះសុទិន និង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ខាងត្បូងទល់ស្រុកពារាំង និង ស្រុកកញ្ជ្រៀច ។ ស៊ីធរកណ្តាលមានផ្ទៃដីសរុប ៣០.៧៦៥ ហិកតា ។

#### **ខ.ចំនួនឃុំ ភូមិ និង ចំនួនគ្រួសារ**

| **ល.រ** | **ឈ្មោះឃុំ** | **ចំនួនភូមិ** | **ចំនួនគ្រួសារ** | **ប្រជាជន** | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ១ | អំពិលក្រៅ | ៥ | ១.៣៧៧ | ៦.៦២១ | ៣.២៩៨ |
| ២ | ឬស្សីសាញ់ | ៤ | ១.៩០៥ | ៨.៧៣៦ | ៤.៥៩៦ |
| ៣ | ព្រៃដើមថ្នឹង | ៤ | ៩៩៣ | ៤.៤៥៧ | ២.៣៦០ |
| ៤ | ពោធិ៍ទី | ៦ | ១.០៧៤ | ៥.៣៦៣ | ២.៩៣០ |

| | | | | | |
|---|---|---|---|---|---|
| ៥ | ព្រៃទឹង | ៥ | ១.៧៣៣ | ៩.១៩៤ | ៤.៨៤៤ |
| ៦ | រំលេច | ៦ | ១.៥៩៦ | ២.៨៥១ | ៤.៣៥១ |
| ៧ | ជ្រៃឃ្មុំ | ៨ | ១.២១៨ | ៦.១៨៧ | ៣.២៣៩ |
| ៨ | ព្នៅទី១ | ៧ | ១.៥៨០ | ៦.៨៥៦ | ៣.៦៣១ |
| ៩ | ព្នៅទី២ | ៤ | ៨២៧ | ៤.២២១ | ២.២៨៩ |
| ១០ | ព្រែកចង្ក្រាន | ៥ | ១.៥៥៦ | ៧.៣៧៨ | ៣.៨៩៥ |
| ១១ | ល្វេ | ៦ | ១.៤០៦ | ៥.៩០៦ | ៣.០៨៨ |
| | **សរុប ១១ ឃុំ** | **៦០ ភូមិ** | **១៥.២៦៥** | **៧៣.១៧០** | **៣៨.៥២១** |

## គ. ចំនួនផ្ទៃដីនិងប្រភេទដី

ស្រុកស៊ិធរកណ្តាលមានផ្ទៃដីសរុប ៣០.៧៦៥ ហិកតា ក្នុងនោះមាន :

- ផ្ទៃដីវស្សា ១៩.៤០០ ហិកតា
- ផ្ទៃដីប្រាំង ១.៧៩៩ ហិកតា
- ផ្ទៃដីចំការ ២៩៤ ហិកតា
- ផ្ទៃដីលំនៅដ្ឋាន ២.៦៤៦ ហិកតា
- ផ្ទៃដីព្រៃ-បឹងបួរ ២.៧៣១ ហិកតា
- ផ្ទៃដីសាធារណៈ ៣.៤៧២ ហិកតា
- ផ្ទៃដីទំនប់ ប្រឡាយ ៤២៣ ហិកតា

### ❑ ពត៌មានលំអិតតាមឃុំ

| លរ | ឈ្មោះ ឃុំ | ផ្ទៃដីសរុប ហ.ត | ផ្ទៃដីបង#បង្កើនផល | | | | ដីព្រៃលិចទឹក | ដី លំនៅដ្ឋាន | ដីទំនប់ប្រឡាយ | ដីសាធារណៈ |
|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប ហ.ត | ដីវស្សា | ដីប្រាំង | ចំការ | | | | |
| ១ | អំពិលក្រៅ | ៣.៧២០ | ២.៨០១ | ២.៨០១ | ០០ | ០០ | ២៤ | ៣៤៣ | ១១០ | ៤៣៧ |
| ២ | ជ្រៃឃ្មុំ | ៤.២០០ | ៣.២៦៨ | ២.៧៦២ | ៥០៦ | ០០ | ៤៣០ | ៣៩១ | ២៦ | ៨៥ |
| ៣ | ល្វេ | ១.៦៣០ | ៤៥២ | ២៥៥ | ១៦៩ | ២៨ | ៦៤ | ៨៤ | ៣៨ | ៩៩២ |
| ៤ | ព្នៅ ទី ១ | ៣.៦៥០ | ២.០១០ | ១.៥៧២ | ២៧៨ | ១៦០ | ៥៤៦ | ១៥១ | ២៩ | ៩១៤ |
| ៥ | ព្នៅ ទី ២ | ៣.២៨០ | ១.៥៧២ | ១.២៣៦ | ៣៣២ | ០៤ | ១.១៥៦ | ៩៧ | ២៩ | ៤២៦ |
| ៦ | ពោធិទី | ២.២៤១ | ១.៩៣៨ | ១.៩៣៨ | ០០ | ០០ | ០០ | ២៥៧ | ២០ | ២៦ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៧ | ព្រៃកចង្រ្កាន | ៦០០ | ១៧៥ | ០០ | ៧៣ | ១០២ | ១៩២ | ១៤១ | ០៦ | ៨៦ |
| ៨ | ព្រៃដើមថ្នឹង | ២.១៣៤ | ១.៦២៦ | ១.៦២៦ | ០០ | ០០ | ២៦៩ | ១៥០ | ២៥ | ៦៤ |
| ៩ | ព្រៃទឹង | ២.៤០០ | ១.៧៩១ | ១.៧៩១ | ០០ | ០០ | ០០ | ៤៧៦ | ៥០ | ៨៣ |
| ១០ | រំលេច | ៣.០៥០ | ២.៦២៩ | ២.២៦៦ | ៣៦៣ | ០០ | ២៥ | ២២៥ | ៣០ | ១៤១ |
| ១១ | ឬស្សីសាញ់ | ៣.៨៦០ | ៣.២៣១ | ៣.១៥៣ | ៧៨ | ០០ | ២៥ | ៣២៦ | ៦០ | ២១៨ |
| **សរុប** | | **៣០.៧៦៥** | **២១.៤៩៣** | **១៩.៤០០** | **១៧.៩៩** | **២៩៤** | **២.៧៣១** | **២.៦៤៦** | **៤២៣** | **៣.៤៧២** |

## ២.២_ទិន្នន័យប្រជាសាស្រ្ត

### ក. ចំនួនប្រជាពលរដ្ឋ

ស្រុកមានប្រជាជនសរុប ១៥.២៦៥ គ្រួសារ មានមនុស្សសរុប : ៧៣.១៧០ នាក់ ស្រី : ៣៨.៥២១ នាក់ ។

**ពត៌មានលំអិតប្រជាជនតាមឃុំ :**

| ល.រ | ឈ្មោះឃុំ | ចំនួនប្រជាជន | | ០_៥ឆ្នាំ | | ៦_១៧ឆ្នាំ | | ១៨_៦០ឆ្នាំ | | ៦១ឆ្នាំឡើង | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | អំពិលក្រៅ | ៦.៦២១ | ៣.២៩៨ | ៥៩៩ | ៣២៦ | ១.៩៦៦ | ១.០៤៧ | ៣.៥១៩ | ១.៦៧៦ | ៥៣៧ | ២៤៩ |
| ២ | ឬស្សីសាញ់ | ៨.៧៣៦ | ៤.៥៩៦ | ១.៣៣៦ | ៦.៨៩ | ២.១៥៦ | ១.១៧៣ | ៤.៤០៣ | ២.៣០១ | ៨៤១ | ៤៣៣ |
| ៣ | ព្រៃដើមថ្នឹង | ៤.៤៥៧ | ២.៣៦០ | ៤៧៤ | ២៣៧ | ១.១៣៩ | ៥៧៤ | ២.៥៤៤ | ១.៣៧៦ | ៣០០ | ១៧៣ |
| ៤ | ពោធិទី | ៥.៣៦៣ | ២.៩៣០ | ៧០០ | ៣៥៣ | ១.៣០០ | ៥៣៧ | ៣.១៦៦ | ១.៩១២ | ១៩៧ | ១២៨ |
| ៥ | ព្រៃទឹង | ៩.១៩៤ | ៤.៨៤៤ | ៩៧៨ | ៥២២ | ២.៣២៣ | ១.១៦២ | ៥.៤៥៩ | ២.៩២៥ | ៤៣៤ | ២៣៥ |
| ៦ | រំលេច | ៨.២៥១ | ៤.៣៥១ | ៧៩៨ | ៤០៥ | ១.៧៩០ | ៩១៤ | ៥.០៨៤ | ២.៧៥១ | ៥៧៩ | ២៨១ |
| ៧ | ល្វេ | ៥.៩០៦ | ៣.០៨៨ | ៥៧៣ | ២៧៩ | ១.៥១៤ | ៨០៣ | ៣.២០៣ | ១.៦៦១ | ៦១៦ | ៣៤៥ |
| ៨ | ព្រៃកចង្រ្កាន | ៧.៣៧៨ | ៣.៨៩៥ | ៦៩៤ | ៣៩០ | ២.០១៣ | ១.០២៨ | ៤.១០៣ | ២.១៧៩ | ៥៦៨ | ២៩៨ |
| ៩ | ព្នៅទី១ | ៦.៨៥៦ | ៣.៦៣១ | ៨២០ | ៤១៤ | ១.៧០៨ | ៨៨៦ | ៣.៧៥៤ | ២.០៥៥ | ៥៧៤ | ២៧៦ |
| ១០ | ព្នៅទី ២ | ៤.២២១ | ២.២៨៩ | ៥៣៨ | ២៨៧ | ១.២៧១ | ៦៨៤ | ២.១៥០ | ១.១៦៨ | ២៦២ | ១៥០ |
| ១១ | ជ្រៃឃ្មុំ | ៦.១៨៧ | ៣.២៣៩ | ៨៧៧ | ៤៦៩ | ១.៧៦៦ | ៩០៥ | ៣.២០៥ | ១.៦៧៧ | ៣៣៩ | ១៨៨ |
| **សរុប** | | ៧៣.១៧០ | ៣៨.៥២១ | ៨.៣៨៧ | ៤.៣៧១ | ១៨.៩៤៦ | ៩.៧១៣ | ៤០.៥៩០ | ២១.៦៨១ | ៥.២៤៧ | ២.៧៥៦ |

### ខ. មុខរបរសំខាន់របស់ប្រជាជន

- ប្រជាជនប្រកបមុខរបរកសិកម្មចំនួន ៩១ %
- ប្រជាជនប្រកបរបរតម្បាញចំនួន ៤ %

- ប្រជាជនប្រកបមុខរបរលក់ដូរចំនួន ៣ %
- ឡើងត្នោត ២ %

## គ. កម្រិតវប្បធម៌

**ចំនួនសិស្សសរុប ឆ្នាំសិក្សា ២០០៨:**

| កម្រិតសិក្សា | ចំនួនសិស្ស | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| មត្តេយ្យ | ១២៧ | ៦៦ | ៦១ |
| មបមសិក្សា | ១០.៨៧៦ | ៥.៧៧៩ | ៥.០៩៧ |
| មធ្យមសិក្សាបឋមភូមិ | ១.៦០២ | ៩០២ | ៧០០ |
| មធ្យមសិក្សាទុតិយភូមិ | ១.៨៤៥ | ១.១៣៧ | ៧០៨ |
| សរុប | ១៤.៤៥០ | ៧.៨៨៤ | ៦.៥៦៦ |

**អ្នកមិនចេះអក្សរ:**

| ល.រ | ឈ្មោះឃុំ | ប្រភេទ អាយុ | ចំនួនអ្នកមិនចេះអក្សរ | | |
|---|---|---|---|---|---|
| | | | **សរុប** | **ប្រុស** | **ស្រី** |
| ១ | អំពិលក្រៅ | ១៥ឆ្នាំ-៦៥ឆ្នាំ | ៦០ | ៣៥ | ២៥ |
| ២ | ជ្រៃឃ្មុំ | ១៥ឆ្នាំ-៦៥ឆ្នាំ | ១៥៤ | ៦០ | ៩៤ |
| ៣ | ល្វេ | ១៥ឆ្នាំ-៦៥ឆ្នាំ | ៥២ | ១៦ | ៣៦ |
| ៤ | ព្នៅទី១ | ១៥ឆ្នាំ-៦៥ឆ្នាំ | ១៩០ | ៨៦ | ១០៤ |
| ៥ | ព្នៅទី២ | ១៥ឆ្នាំ-៦៥ឆ្នាំ | ៦១ | ២៥ | ៣៦ |
| ៦ | ពោធិទី | ១៥ឆ្នាំ-៦៥ឆ្នាំ | ១១១ | ៥៤ | ៥៧ |
| ៧ | ព្រែកចង្ក្រាន | ១៥ឆ្នាំ-៦៥ឆ្នាំ | ១៣៨ | ៥៣ | ៨៥ |
| ៨ | ព្រៃដើមថ្នឹង | ១៥ឆ្នាំ-៦៥ឆ្នាំ | ៧៥ | ៣៥ | ៤០ |
| ៩ | ព្រៃទឹង | ១៥ឆ្នាំ-៦៥ឆ្នាំ | ១៨៨ | ៨៩ | ៩៩ |
| ១០ | រំលេច | ១៥ឆ្នាំ-៦៥ឆ្នាំ | ៦១ | ២៦ | ៣៥ |
| ១១ | ឫស្សីសាញ់ | ១៥ឆ្នាំ-៦៥ឆ្នាំ | ៣៨ | ១៦ | ២២ |
| **សរុប** | | | **១១២៨** | **៤៩៥** | **៦៣៣** |

## ឃ. សេដ្ឋកិច្ច

- ❑ **កម្រិតអត្រានៃភាពក្រីក្រ :**

- អ្នកក្រីក្រមាន ៥៥ % មធ្យម ៣០ % គ្រាន់បើ ១៥ %

- **សកម្មភាពចំណូល :**
  - ប្រជាជនក្រីក្រសរុប ៩៥ % រកចំណូលបានតិចជាង ៥០០៛ក្នុង ១ ថ្ងៃ ។
  - អ្នកក្រមធ្យម ៣០% អាចរកចំណូលបានពី ៥០០៛ ទៅ ៥០០០៛ ក្នុង ១ ថ្ងៃ
  - អ្នកលក់ដូរអាជីវករ-សិប្បករ ១៥ % អាចរកចំណូលពី ៣០០០៛ ទៅ៥០០០៛យ៉ាងតិចក្នុង ១ ថ្ងៃ ។

  *( ព័ត៌មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ស៊ីធរកណ្តាល )*

- **ចំនួនស្ត្រីជាមេគ្រួសារ :**

  ចំនួនស្ត្រីជាមេគ្រួសារមាន ៣.៧៣៣ នាក់ ស្មើនឹង ២៤.៤៥ % នៃគ្រួសារសរុប ១៥.២៦៥

- **កម្លាំងពលកម្ម :**

  កម្លាំងពលកម្មពីអាយុ ១៨ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៤០.៥៩០ នាក់ ដោយមិនគិតកុមារក្រោមអាយុ ១៨ ឆ្នាំ និង មនុស្សចាស់លើសពីអាយុ ៦១ ឆ្នាំ ឡើង ។

- **ចំណាកស្រុក :**

  ក្នុងឆ្នាំ ២០០៧- ២០០៨ នេះ ទោះគ្រោះធម្មជាតិពុំមានកើតឡើងធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋមួយចំនួនបានធ្វើចំណាកស្រុកចេញទៅរកការងារធ្វើនៅតាម ទីក្រុងនិងខេត្តនានា និងមួយចំនួន ទៀតទៅប្រទេសថៃ ។ សរុបប្រជាជនចំណាកស្រុកចំនួន ១៧ % ក្នុងនោះ អ្នកដែលមានមុខរបរច្បាស់លាស់ ១៥.៤០ % និង មិនច្បាស់លាស់ ១.៦០% ។

## ២.៣~ប្រវត្តិគ្រោះមហន្តរាយ

ស្រុកស៊ីធរកណ្តាលជាតំបន់វាលទំនាប ស្ថិតនៅជាប់ដងទន្លេតូច ជាមួយស្រុកកោះសុទិនខេត្តកំពង់ចាម និងងាយទទួលរងឥទ្ធិពលទឹកជំនន់ ពីដងទន្លេមេគង្គមុនស្រុកនានាក្នុងខេត្តព្រៃវែង។ ទន្លេតូចនេះ កាត់ស្រុកស៊ីធរកណ្តាល ស្រុកពារាំង ស្រុកកំពង់លាវ ស្រុកពាមរក៏ និង ស្រុកពាមជរ។ នៅរដូវទឹកជំនន់ទន្លេមេគង្គ ទន្លេតូចនេះ ហៀរចាក់មកគ្របដណ្តប់ លើស្រុកខាងលើ ព្រមទាំងជិតពាក់កណ្តាលផ្ទៃដីស្រុកព្រៃវែង ស្រុកបាភ្នំ ស្រុកព្រះស្តេចស្រុក កំពង់ត្របែក និងមួយចំណែកតូចនៃស្រុកកញ្ជ្រៀច។ ដោយសារស្រុក មានទីតាំងភូមិសាស្ត្របែបនេះ ទើបស្រុកត្រូវងាយរងគ្រោះ យ៉ាងធ្ងន់ធ្ងរពីទឹកជំនន់ ជាប់ៗគ្នា ពីឆ្នាំ ២០០០-២០០១ -២០០២ ២០០៣ - ២០០៤ និង ២០០៥ ។

### ក. ការវិភាគលើមុខសញ្ញាបង្កគ្រោះថ្នាក់នានាពីឆ្នាំ ២០០២-២០០៨

| មុខសញ្ញា | ឥទ្ធិពល និង ភាពធ្ងន់ធ្ងរ | | | | | | | | | | ពេលវេលា | រយៈពេល | ល្បឿន | គ្រោះថ្នាក់ដែលអាចកើតឡើង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៩៩ | ០០ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | | | | |
| ទឹកជំនន់ | x | xxx | xxx | xxx | x | x | x | x | x | x | កក្កដា-តុលា | ៣ខែ | យឺតៗ | -មនុស្ស<br>-ដំណាំកសិកម្ម |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | -សត្វ<br>-ហេដ្ឋារចនាសម្ព័ន្ធ |
| រាំងស្ងួត | | xx | xx | xx | x | xx | x | x | x | x | ឧសភា<br>មិថុនា | ២ ខែ | យឺតៗ | -មនុស្ស-សត្វ-ជំងឺ<br>-ដំណាំកសិកម្ម |
| ខ្យល់ព្យុះ | | xx | xx | xx | | x | | x | x | x | កក្កដា កញ្ញា | ៣ ខែ | លឿន | -មនុស្ស-សត្វ<br>-<br>អាគារ.ផ្ទះ.ហេដ្ឋារចនាសម្ព័ន្ធ |
| ផាសាយបក្សី | | | | | | | | | | | | | | |

**<u>កំណត់សម្គាល់</u>**

XXX: ធ្ងន់ធ្ងរ XX: មធ្យម X: តិចតួច

## ខ. ការវិភាគភាពងាយរងគ្រោះ

ឃុំដែលងាយរងគ្រោះ ដោយទឹកជំនន់ និងទទួលការប៉ះពាល់ធ្ងន់ធ្ងរជាងគេមាន ៨ ឃុំ គឺឃុំ អំពិលក្រៅ ព្រៃទឹង ព្នៅទី១ ព្នៅទី២ ជ្រៃឃ្មុំ ព្រែកចង្ក្រាន រំលេច និង ឃុំល្វេ ដែលមានភូមិសរុបចំនួន ៣១ ភូមិ ។

- **ភាពងាយរងគ្រោះវិស័យហេដ្ឋារចនាសម្ព័ន្ធ**

| ល.រ | ឈ្មោះឃុំ | ទំនប់<br>ម | ប្រឡាយ<br>ម | សាលារៀន<br>កន្លែង | មណ្ឌលសុខភាព<br>ចំនួន | វត្តចំនួន | អាគារចំនួន | ផ្លូវលំ<br>ម |
|---|---|---|---|---|---|---|---|---|
| ១ | អំពិលក្រៅ | | | ០៣ | | ០៥ | | ២.៨០០ |
| ២ | ឫស្សីសាញ់ | | ១.៣០០ | ០១ | | | | |
| ៣ | ព្រៃដើមថ្នឹង | | ២.៥០០ | | ០១ | | | |
| ៤ | ពោធិទី | ៤.៣៥០ | | | | ០១ | | |
| ៥ | ព្រៃទឹង | | | ០១ | | ០ | | |
| ៦ | រំលេច | | | ០១ | | ០២ | | |
| ៧ | ព្នៅទី១ | ១.៤២៥ | ៧.០០០ | ០៣ | | ០២ | | ១៧.២០០ |
| ៨ | ព្នៅទី២ | | | ០៤ | | ០៤ | | |
| ៩ | ជ្រៃឃ្មុំ | | | ០២ | | ០៣ | | |
| ១០ | ព្រែកចង្ក្រាន | | | ០៥ | | ០៤ | | |
| ១១ | ល្វេ | | | ០៤ | | | | |

## គ. ផែនទីគ្រោះមហន្តរាយទឹកជំនន់ ឆ្នាំ២០០០របស់ស្រុកស៊ីធរកណ្តាល



## ២.៤-ធនធានសំខាន់ៗ

### ក. សាលារៀននៅឆ្នាំ២០០៨

| ល.រ | ឈ្មោះឃុំ | បឋមសិក្សា | | | មធ្យមសិក្សា | | |
|---|---|---|---|---|---|---|---|
| | | ចំនួនខ្នង | បន្ទប់ | ចំនួនគ្រូ | ចំនួនខ្នង | បន្ទប់ | ចំនួនគ្រូ |
| ១ | អំពិលក្រៅ | ១១ | ៣៤ | ២៦ | ០១ | ០៥ | ០៧ |
| ២ | ឫស្សីសាញ់ | ០៨ | ៣០ | ២១ | ០៣ | ១៣ | ១០ |
| ៣ | ព្រៃដើមថ្នឹង | ០៥ | ១៤ | ២១ | ០៥ | ២២ | ២៤ |
| ៤ | ពោធិទី | ០៤ | ២០ | ១៦ | ០១ | ០៥ | ០៥ |
| ៥ | ព្រៃទឹង | ១០ | ៣៨ | ៣០ | ០១ | ០៥ | ០៧ |
| ៦ | រំលេច | ១២ | ៤៦ | ៣២ | ០១ | ០៥ | ០៧ |
| ៧ | ជ្រៃឃ្មុំ | ០៦ | ២៧ | ២០ | ០១ | ០៥ | ០៤ |
| ៨ | ព្នៅទី១ | ០៨ | ៣៤ | ២១ | ០៤ | ១៥ | ១៤ |
| ៩ | ព្នៅទី២ | ០៧ | ២៤ | ១៣ | ០១ | ០៥ | ០៨ |
| ១០ | ព្រែកចង្ក្រាន | ១០ | ៤៥ | ៣៤ | ០៦ | ៣៣ | ៥៤ |
| ១១ | ល្វេ | ០៩ | ៤១ | ១៨ | ០១ | ០៥ | ០៤ |
| | **សរុប** | ៩០ | ៣៩៣ | ២៥២ | ២៥ | ១១៨ | ១៤៤ |

### ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ

ស្រុកស៊ីធរកណ្តាលគ្មាន ស្រុកប្រតិបត្តិ ទេ និងមាន មណ្ឌលសុខភាព ០៦ កន្លែងដូចខាងក្រោមៈ

| លរ | ឈ្មោះមណ្ឌលសុខភាព/ ស្រុកប្រតិបត្តិ | ឃុំ | ចំនួនមន្ត្រីពេទ្យ | | | |
|---|---|---|---|---|---|---|
| | | | វេជ្ជបណ្ឌិត | គ្រូពេទ្យ | គិលានុបដ្ឋាក | ឆ្មប |
| ១ | មណ្ឌលសុខភាពព្រែកចង្ក្រាន | ព្រែកចង្ក្រាន | ១ | ០ | ៧( ស្រី ១) | ២ ( ស្រី) |
| ២ | មណ្ឌលសុខភាពព្នៅ | ព្នៅ | ០ | ០ | ៥( ស្រី ១) | ១( ស្រី) |
| ៣ | មណ្ឌលសុខភាពជ្រៃឃ្មុំ | ជ្រៃឃ្មុំ | ០ | ០ | ៤( ស្រី ១) | ១( ស្រី) |
| ៤ | មណ្ឌលសុខភាពរំលេច | រំលេច | ០ | ០ | ៣ | ១( ស្រី) |
| ៥ | មណ្ឌលសុខភាពព្រៃដើមថ្នឹង | ព្រៃដើមថ្នឹង | ០ | ២ | ៥( ស្រី ១) | ៣( ស្រី) |
| ៦ | មណ្ឌលសុខភាពពោធិទី | ពោធិទី | ០ | ០ | ៤ | ២( ស្រី) |
| **សរុប** | | | **១** | **២** | **២៨**ស្រី ៤) | **១០**( ស្រី) |

### គ. ទីទួលសុវត្ថិភាព និង ទីតាំង

តាមពត៌មានពីគណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ស៊ីធរកណ្តាល បានបញ្ជាក់ថា នៅទូទាំងស្រុក មានទីទួល សុវត្ថិភាព ចំនួន ២៦កន្លែង ហើយដែលពុំទាន់បានរៀបរយនៅឡើយ ។

### ឃ. មធ្យោបាយដឹកជញ្ជូន

| ល.រ | ឈ្មោះឃុំ | ម៉ូតូ | ត្រាក់ទ័រ គោយន្ត.រថយន្ត | រទេះគោនិង រទេះសេះ | កង់ | ទូកចែវ ទូកអុំ | ទូកម៉ាស៊ីន ការណូត |
|---|---|---|---|---|---|---|---|
| ១ | អំពិលក្រៅ | ១៥៦ | ១០ | ៣០៧ | ៦៥៩ | ២០ | ១៦ |
| ២ | ឬស្សីសាញ់ | ១៩៣ | ០៣ | ៥៧៨ | ៤២០ | ១០ | |
| ៣ | ព្រៃដើមថ្នឹង | ១៨៩ | ០៧ | ២៩៨ | ៧៥១ | ០៤ | ០៥ |
| ៤ | ពោធិ៍ទី | ១៣៥ | ១៣ | ៣៥៥ | ៤០៤ | | |
| ៥ | ព្រៃទឹង | ២២៥ | ០៧ | ៦៤៤ | ១.៣២១ | ០១ | ០៤ |
| ៦ | រំលេច | ៣៩៤ | ១២ | ៧២២ | ៨៨៥ | ១០៤ | ១០ |
| ៧ | ល្វេ | ១៧៦ | ០៦ | ៣០២ | ៥៣០ | ២៧០ | ២៣ |
| ៨ | ព្រែកចង្ក្រាន | ៤២៩ | ១៩ | ៧៨៩ | ១៣៩៧ | ១៤៧៩ | ៧៥ |
| ៩ | ព្នៅទី១ | ១៦១ | ០៣ | ៣៧១ | ៧២១ | ១៩៥ | ១៨ |
| ១០ | ព្នៅទី២ | ១០៤ | ០៣ | ៣២២ | ៤៧០ | ១០៧ | ២៥ |
| ១១ | ជ្រៃឃ្មុំ | ១៤៨ | ០៦ | ៥៦៥ | ៥៥៩ | ១៤៤ | ១៣ |
| | **សរុប** | **២៣១០** | **៨៩** | **៥២៥៣** | **៨១១៧** | **២៣៣៤** | **១៨៩** |

### ង. ប្រព័ន្ធធារាសាស្ត្រ

- ស្រុកមានទំនប់ស្តុកទឹក ១ កន្លែង គឺ ទំនប់ឡាំឡូង ស្ថិតនៅក្នុងឃុំជ្រៃឃ្មុំ សម្រាប់ប្រជាជនប្រើប្រាស់ និង ស្រោចស្រពស្រូវវស្សាប្រាំង ។
- **ទន្លេសំខាន់ៗ**

  ស្រុកស៊ីធរកណ្តាលមាន ៤ ឃុំ ស្ថិតនៅជាប់ដងទន្លេតូច គឺ ឃុំ ល្វេ ព្រែកចង្ក្រាន ព្នៅទី១ ព្នៅទី២ ដែលមានព្រំប្រទល់ ជាប់ជាមួយស្រុកកោះសុទិន ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និង ស្រុកពាំរាំង ខេត្តព្រៃវែង ។
- **ប្រភពទឹកផ្សេងៗទៀត**

ជារៀងរាល់ឆ្នាំ ទន្លេមេគង្គបានហូរចាត់ចូលទន្លេតូច សាយភាយនូវពពួកបច្ចាជាតិ សម្រាប់ផ្គត់ផ្គង់ជីវភាព ប្រជាជនយើង។ ជាមួយគ្នានេះដែរ ស្រុកក៏មានបឹងតូចៗចំនួន ០៥ កន្លែងគឺ បឹងស្រះអង្គាម បឹងផ្តោល បឹងឬស្សី បឹងប្រិយ៍ និង បឹងរំលេច ដែលដឹកល់ទឹកសម្រាប់ សត្វពាហនៈ និង ការនេសាទជាលក្ខណៈគ្រួសារ របស់ប្រជាជន។

- **ធនធានមនុស្ស**
  - មន្ត្រីសាលាស្រុក និង ការិយាល័យជុំវិញស្រុក
  - កងកម្លាំងប្រដាប់អាវុធទាំងបី
  - អាជ្ញាធរមូលដ្ឋាន

## ច. ប្រព័ន្ធទំនាក់ទំនង

| ល.រ | គោត្តនាម_នាម | មុខងារ | អង្គភាព | លេខទូរសព្ទ |
|---|---|---|---|---|
| ១ | ល. កោ អ៊ឹម | អភិបាលស្រុក | ស៊ីធរកណ្តាល | ០១២ ៣២២ ៣៣១ |
| ២ | ល.ពា គីមយាង | អភិបាលរងស្រុក | " | ០១២ ៧៨៣ ៣២៥ |
| ៣ | ល.ជុំ ជាន | អភិបាលរងស្រុក | " | ០១២ ៦០២ ៣១៥ |
| ៤ | ល. អាន ស្រឿន | អភិបាលរងស្រុក | " | ០១២ ៣៧៨២៦៣ |
| ៥ | លស.វង្ស សារ៉ែន | អភិបាលរងស្រុក | " | ០១២ ៦២៤ ៧៣២ |
| ៦ | ល.យ៉ុន សុខណេត | អធិការនរគបាល | នរគបាល | ០១២ ៩៦៣ ៦៩៤ |
| ៧ | ល. សោម សាម៉ន | ប្រធានការិ.ស្រុក | " | ០១២ ១៩០ ៥ ៧៧២ |
| ៨ | ល.នុន ថូ | ប្រធានការិ. | អប់រំស្រុក | ០១២ ៣០៩ ៨៤៨ |
| ៩ | ល.ជាម ឈឿន | ប្រធានការិ. | សុខាភិបាលស្រុក | ០១២ ៣១ ៥១២ |
| ១០ | ល.មុំ ប៉ុម | ប្រធានការិ. | ភូមិបាលស្រុក | ០៩២ ២៨៦ ២៧០ |
| ១១ | ល.សាង ហ៊ាង | ប្រធានការិ | .កសិកម្មស្រុក | ០១២ ២៦៧ ២៥៨ |
| ១២ | ល.ទុប វិបុល | ប្រធានការិ. | សង្គមកិច្ចស្រុក | ០១២៤៣៩ ១៩៤ |
| ១៣ | ល.អ៊ុក វ៉ាយ | មេបញ្ជាការ | កងរាជអាវុធហត | ០១២ ២៣៨ ៩៨១ |
| ១៤ | លស.ធី ថុល | ប្រធានការិ. | អភិវឌ្ឍន៏ស្រុក | ០១៧ ៥៧៧ ២៩៦ |
| ១៥ | ល.បែន បយ | ប្រធានការិ. | ហិរញ្ញវត្ថុស្រុក | ០១២ ២៣៨ ៩៨១ |
| ១៦ | ល.ឃុន យ៉ុន | បញ្ជាការ | សីករងស្រុក | ១៧៧៧ ២៩៦ |

# ៣. ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## ៣.១-ក្របខណ្ឌការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ផែនការសកម្មភាពដែលបានលើកឡើងដោយផ្អែកលើក្របខ័ណ្ឌការងារសកម្មភាពយោហ្គោ(HFA) គឺបានរៀបចំក្នុងគម្រោង ការគ្រប់ជ្រុងជ្រោយមួយដើម្បីចង្អុលណែនាំអំពីការឆ្លើយតបរបស់អ្នកពាក់ព័ន្ធលើ ការដោះស្រាយផលប៉ះពាល់នៃគ្រោះមហន្តរាយ ។ ប៉ុន្តែការសង្កត់ធ្ងន់ត្រូវបានតម្រង់ ទៅរកការពង្រឹង សមត្ថ ភាពថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ដោយកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់ ការផ្តួចផ្តើម ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងដើម្បីគាំទ្រដល់ការសម្រេចឱ្យបាននូវ គោល បំណងកាត់បន្ថយភាពក្រីក្ររបស់ប្រទេស ដែលមាននៅក្នុងផែនការ និងគោលនយោបាយជាតិ(NSDP) ២០០៦-២០១០, NPRS, CMDG, NAPA ២០០៦) ។

សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមានចំនួន ០៦សំខាន់ ដែលបានកំណត់ ជាអាទិភាព សម្រាប់ប្រទេសកម្ពុជា ដូចខាងក្រោម :

**១-ធានាឱ្យបាននូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គឺជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន**

១.១-រៀបចំជាក់លាក់គោលនយោបាយជាតិ និង នីតិកម្ម ក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ

១.២-បង្កើត និងពង្រឹងយន្តការសម្របសម្រួលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅថ្នាក់ ជាតិ ឬ"កម្មវិធីជាតិស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ"

១.៣-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការ និងគោលនយោបាយ អភិវឌ្ឍជាតិ

១.៤-ចាត់ចំណាយធនធានសមស្របសម្រាប់ការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ជាតិ ។

**២- ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍**

២.១-វិមជ្ឈការការទទួលខុសត្រូវ និងធនធានសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

២.២-លើកកម្ពស់ការអនុវត្ត កម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ។

**៣- កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និងលើកកម្ពស់ការផ្តល់ដំណឹងជាមុន**

៣.១-ធ្វើការប៉ាន់ប្រមាណ ពីគ្រោះភ័យនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

៣.២-បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ

៣.៣-កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់

៣.៤-សហការជាមួយ អង្គការអន្តរជាតិ និង អង្គការថ្នាក់តំបន់ លើកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយ គ្រោះ ភ័យនៃគ្រោះមហន្តរាយ ។

**៤- ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាពនិងសមត្ថភាពទប់ទល់**

**បាននៅគ្រប់ថ្នាក់**

៤.១-បង្កើតយន្តការសម្រាប់បណ្ដាញការងារ និងការផ្លាស់ប្ដូរព័ត៌មាន

៤.២-លើកកម្ពស់ការអប់រំ និងបណ្ដុះបណ្ដាលអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៣-លើកកម្ពស់ការបណ្ដុះបណ្ដាល យេនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួម របស់ការ កាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៤-ដំណើរការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងបច្ចេកទេសអំពីការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៥-បង្កើនការយល់ដឹងជាសាធារណៈ

**៥- ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានា របស់ក្រសួងពាក់ព័ន្ធ**

៥.១-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង និរន្តរភាពបរិស្ថាន

៥.២-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីសកម្មភាពជាតិ បន្សុំានឹងការប្រែប្រួលអាកាសធាតុ

៥.៣-បង្កើនសន្តិសុខស្បៀងដើម្បីបង្កើនសមត្ថភាពធន់ទ្រាំរបស់សហគមន៍

៥.៤-ធ្វើសមាហរណកម្មផែនការការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងវិស័យសុខាភិបាល

៥.៥-លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបានសមស្រប

៥.៦-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី និង វិធានការបច្ចេកទេសផ្សេងៗទៀត

៥.៧-បង្កើតទម្រង់បែបបទហិរញ្ញវត្ថុសម្រាប់ការដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ

**៦-ពង្រឹងការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់**

៦.១-ពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតប

៦.២-បង្កើតនូវយន្តការប្រតិបត្តិការសម្របសម្រួលថ្នាក់តំបន់ សម្រាប់ការងារសង្គ្រោះបន្ទាន់ ដែលហួសពីសមត្ថភាពដោះស្រាយនៅថ្នាក់ជាតិ

៦.៣-រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមពេលវេលាលើការរៀបចំផែនការបម្រុងទុក និងការត្រៀមរៀបចំ សម្រាប់គ្រោះមហន្តរាយ

៦.៤-បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់ ។

## ៣.២_តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

| សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ | | រយះពេល | | | ថវិកាដាក់លាក់សម្រាប់រយះពេលខ្លី(000ដុល្លារ) |
|---|---|---|---|---|---|
| | | S | M | L | |
| 1 | **ធានាឱ្យបាននូវ DRR គឺជាអាទិភាពនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ប្រកបដោយគ្រឹះនៃស្ថាប័នរឹងមាំសម្រាប់ការអនុវត្តន៏** | | | | |
| 1.1 | រៀបចំដាក់លាក់គោលនយោបាយជាតិ និងនីតិកម្មគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ថ្នាក់ជាតិ | * | | | 100 |
| 1.2 | ការបង្កើត និងពង្រឹងយន្តការសម្របសម្រួល DRR ថ្នាក់ជាតិ – កម្មវិធីជាតិស្តីពី DRR | * | | | 300 |
| 1.3 | សមាហរណកម្ម DRR ទៅក្នុងគោលនយោបាយ និងការរៀបចំផែនការអភិវឌ្ឍជាតិ | * | | | 100 |
| 1.4 | ការចាត់ចំណាយធនធានសមស្របសម្រាប់ការងារ DRR នៅថ្នាក់ជាតិ | | | | |
| 2 | **ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៏** | | | | |
| 2.1 | វិមជ្ឈការនៃការទទួលខុសត្រូវ និងធនធានសម្រាប់ DRR | | | | |
| 2.2 | លើកកម្ពស់ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋាន-សហគមន៏ | | | | 550 |
| 3 | **កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និង លើកកម្ពស់ការផ្តល់ដំណឹងជាមុន** | | | | |
| 3.1 | ដំណើរការប៉ាន់ប្រមាណគ្រោះភ័យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន | | | | |
| 3.2 | បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ | | | | |
| 3.3 | កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់ | | | | |
| 3.4 | សហប្រតិបត្តិការជាមួយ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិនៃកិច្ចខិតខំប្រឹងប្រែងលើ DRR | | | | |
| 4 | **ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំដើម្បីកសាងវប្បធម៌សុវត្ថិភាព និង សមត្ថភាពទប់ទល់បាននៅគ្រប់ថ្នាក់** | | | | |
| 4.1 | បង្កើតយន្តការសម្រាប់បណ្តាញការងារ និងផ្លាស់ប្តូរព័ត៌មាន | | | | |
| 4.2 | លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលអំពី DRR | | | | |
| 4.3 | លើកកម្ពស់ការបណ្តុះបណ្តាលពីយិនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួម របស់ DRR | | | | |
| 4.4 | ផ្តើមធ្វើការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងបច្ចេកទេសអំពីការគ្រប់គ្រង DRR | | | | |
| 4.5 | បង្កើនការយល់ដឹងជាសាធារណៈ | | | | |
| 5 | **បញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ក្រសួងពាក់ព័ន្ធ** | | | | |
| 5.1 | រួមបញ្ចូល DRR ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តភាព | | | | |
| 5.2 | សមាហរណកម្មការងារ DRR ទៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួល អាកាសធាតុ | | | | |
| 5.3 | បង្កើនសន្តិសុខស្បៀងដើម្បីលើកកម្ពស់សមត្ថភាពអាចទប់ទល់បានរបស់សហគមន៏ | | | | |
| 5.4 | លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបាន សមស្រប | | | | |
| 5.5 | សមាហរណកម្មការធ្វើផែនការ DRR ទៅក្នុងវិស័យសុខាភិបាល | | | | |

| | | | | | |
|---|---|---|---|---|---|
| 5.6 | រួមបញ្ចូល DRR ទៅក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីនិងវិធានការបច្ចេកទេសដទៃទៀត | | | | 150 |
| 5.7 | បង្កើតទម្រង់បែបបទឯកសារហិរញ្ញវត្ថុសម្រាប់ដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ | | | | |
| 6 | **ពង្រឹងការត្រៀមរៀបចំសម្រាប់ការឆ្លើយតបគ្រោះមហន្តរាយ ឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់** | | | | |
| 6.1 | ពង្រឹងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងការឆ្លើយតប | | | | 400 |
| 6.2 | បង្កើតយន្តការប្រតិបត្តិការ សម្របសម្រួលសម្រាប់ការសង្គ្រោះបន្ទាន់ ដែលហួសសមត្ថភាពដោះស្រាយនៅថ្នាក់ជាតិ | | | | |
| 6.3 | រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមដំណាក់កាលលើការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ និងផែនការបម្រុងទុកជាមុន | | | | |
| 6.4 | បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់ | | | | |
| | **សរុបរួម** | | | | 2,000 |

***កំណត់សម្គាល់ :***

- * - កម្មវិធីត្រូវអនុវត្តបន្ទាន់ (ឆ្នាំទី១)
- S - កម្មវិធីរយៈពេលខ្លី (១-២ ឆ្នាំ)
- M - កម្មវិធីរយៈពេលមធ្យម (៣-៤ ឆ្នាំ)
- L - កម្មវិធីរយៈពេលវែង (៥-៧ ឆ្នាំ)

# ៤. យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ

## ៤.១_សមាសភាព

១. អភិបាល ស្រុក — ជាប្រធាន

២. អភិបាលរង០១រូប — ជាអនុប្រធាន

៣. កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ និងការិយាល័យជុំវិញស្រុក — ជាសមាជិក

៤. ប្រធានការិយាល័យសាលាស្រុក ជាលេខាអចិន្ត្រៃយ៍ និង ប្រធានការិយាល័យចំនួន ០៣រូប ជាជំនួយការ។

## ៤.២_តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

ការដឹកនាំ បញ្ជា និងសម្រេចកិច្ចការរបស់គណៈកម្មា ធិការ គ្រប់គ្រងគ្រោះមហន្តរាយស្រុក ត្រូវបានធ្វើឡើងដោយអភិបាលរសុកដែលជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។ ភារកិច្ចជារួមរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក មានដូចខាងក្រោម :

១. អនុវត្តគោលការណ៍ ដែលទាក់ទងទៅនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំជាសាធារណៈនៅក្នុងសហគមន៍

២. ទំនាក់ទំនង និងផ្តល់ព័ត៌មានទាន់ពេលវេលា ជូន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

៣. ត្រៀមបង្ការទប់ទល់គ្រប់កាលៈទេសៈ

៤. សហប្រតិបត្តិការ នៅពេលកើតមានគ្រោះមហន្តរាយ

៥. ធ្វើរបាយការណ៍ជូនទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ធ្វើផែនការកម្មវិធី លើកគម្រោង ស្តីពីការខូចខាត និងធ្វើសំណើសុំជាថវិកា សម្ភា មធ្យោបាយ ដឹកនាំដោយផ្ទាល់កិច្ចប្រតិបត្តិការក្នុងពេលមាន គ្រោះមហន្តរាយ រួមមាន ជំនួយសង្គ្រោះ ការជម្លៀស ការផ្តល់ទីជម្រក និងការផ្តល់ជំនួយសុខាភិបាល...។

៦. ជួយសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ

៧. ទំនាក់ទំនង និងអំពាវនាវដល់កាកបាទក្រហមកម្ពុជា អង្គការមនុស្សធម៌ជាតិ-អន្តរជាតិ សមាគមនានា ដើម្បី ចូលរួមជួយសហការឧបត្ថម្ភដល់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

## ៤.៣-រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក



## ៤.៤-ក្រុមប្រតិបត្តិការ

| ក្រុមស្រាវជ្រាវរុករកសង្គ្រោះ និង ការពារសន្តិសុខ | |
|---|---|
| **សមាសភាពអនុប្រធាន** | **តួនាទី និង ការទទួលខុសត្រូវ** |
| អធិការនគរបាលស្រុក | តាមដានព័ត៌មាន និង របាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ ដើម្បីត្រៀមលក្ខណៈ និង ប្រតិបត្តិការសង្គ្រោះ។ |
| បញ្ជាការផ្នែកសឹករងស្រុក | ជួយសង្គ្រោះប្រជាជនដែលងាយរងគ្រោះ និង ប្រជាជនរងគ្រោះ ដោយសារគ្រោះមហន្តរាយទឹកជំនន់ ។ |
| បញ្ជាការកងអាវុធហត្ថស្រុក | កំណត់ប្រជាជនដែលស្ថិតនៅតំបន់ប្រឈមមុខនិងតំបន់ងាយរងគ្រោះ។ |
| **សមាសភាពសមាជិក :** | ជួយអាជ្ញាធរភូមិ ឃុំ និង ក្រុមប្រតិបត្តិការដទៃទៀតទៅតាម ការស្នើសុំជាក់ស្តែង។ |
| ប្រធានការិ.អភិវឌ្ឍន៍ជនបទ | សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់នៅទីសុវត្ថិភាពដែលជន រងគ្រោះស្នាក់នៅ និងការពារទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាជនដែលបានភៀសខ្លួន។ |
| ប្រធានការិ.ភូមិបាលស្រុក | សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីគ្រប់គ្រង និង សង់ជំរក បណ្តោះអាសន្ននៅទីទួលសុវត្ថិភាព។ |
| អនុប្រធានស្រុកប្រតិបត្តិប្រចាំស្រុកស៊ីធរ កណ្តាល | ផ្តល់ពតិមានពាក់ព័ន្ធដល់អាជ្ញាធរភូមិ ឃុំ និង ចែករំលែកព័ត៌មាន ពាក់ព័ន្ធជាប្រចាំដល់ក្រុមដទៃ ការិយាល័យ និង អង្គភាព និង អង្គការនានានៅក្នុងស្រុក។ |
| លេខាធិការដ្ឋានអចិន្ត្រៃយ៍ស្រុក | សហការ និង ជួយសំរបសម្រួលដល់អាជ្ញាធរភូមិ ឃុំ អង្គការនានា ពាក់ព័ន្ធក្នុងការជម្លៀស និងសង្គ្រោះ។ |
| ប្រធានការិយាល័យ កិច្ចការនារី | ជួយសំរបសម្រួល និង ការពារមធ្យោបាយដឹកជញ្ជូនសំភារៈជំនួយ និង ជួយដឹកប្រជាពលរដ្ឋរងគ្រោះ។ |
| អង្គការនានា | ធ្វើការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីកំណត់មធ្យោបាយ និង ឧបករណ៍សម្រាប់បំរើឱ្យការងារជម្លៀស និង សង្គ្រោះ។ |
| | ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងចូលរួមការប្រជុំផ្សេងទៀតតាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។ |
| | តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក។ |

| ក្រុមសុខភាព អនាម័យ និងទឹកស្អាត | |
|---|---|
| **សមាសភាពអនុប្រធាន :** | **តួនាទី និង ការទទួលខុសត្រូវ** |
| អនុប្រធានស្រុកប្រតិបត្តិប្រចាំស្រុក ស៊ីធរកណ្តាល ប្រធានការិ. អភិវឌ្ឍន៍ជនបទស្រុក | សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីផ្តល់ការអប់រំនិងផ្សព្វផ្សាយ ក្នុងការថែទាំសុខភាព អនាម័យ និងការ ប្រើប្រាស់ទឹកស្អាត និង បង្ការជំងឺរាតត្បាតផ្សេង ៗ។ |
| **សមាសភាពសមាជិក :** | ផ្តល់ការហ្វឹកហ្វឺនវិជ្ជាសង្គ្រោះបឋមដល់ក្រុមស្រាវជ្រាវនិងសង្គ្រោះ និង ក្រុមអ្នកស្ម័គ្រចិត្តតាមសហគមន៍។ |
| អធិការនគរបាលស្រុក<br>ប្រធានអនុសាខាកាកបាទក្រហម (អនុប្រធាន)<br>ផ្នែកបសុព្យាបាលស្រុក<br>ប្រធានការិ បរិស្ថានស្រុក<br>ប្រធានការិ កិច្ចការនារី<br>អង្គការនានានៅក្នុងស្រុក | សហការជាមួយមណ្ឌលសុខភាពនានា និង អាជ្ញាធរភូមិ ឃុំ ដើម្បី ប្រតិបត្តិការសង្គ្រោះបន្ទាន់ និង ព្យាបាល ដល់ប្រជាជនរងគ្រោះ ដោយសារគ្រោះថ្នាក់ផ្សេងៗ ។<br>ចុះត្រួតពិនិត្យ ចាក់ថ្នាំបង្ការ និង ព្យាបាលសត្វពាហនៈគ្រប់ប្រភេទ<br>សហការជាមួយអាជ្ញាធរភូមិ ឃុំ និង មណ្ឌលសុខភាពនានា ដើម្បីតាមដានត្រួតពិនិត្យបញ្ហាទាក់ទងនឹងសុខភាព អនាម័យ ទឹកស្អាត និង បញ្ហាជំងឺផ្សេងៗទៀត ដែលបណ្តាលមកពីមុខសញ្ញាបង្ករគ្រោះមហន្តរាយនានា។<br>ដឹកនាំ និង សហការជាមួយមណ្ឌលសុខភាព និង អាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់ និង សេចក្តីត្រូវការ ផ្នែកសុខភាព អនាម័យ និងទឹកស្អាត។<br>ធ្វើរបាយការណ៍ពីស្ថានភាពទាក់ទងនឹងសុខភាព អនាម័យ ទឹកស្អាតនិងជំងឺរាតត្បាតផ្សេងៗ ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយស្រុក-ខេត្ត និងអង្គភាពពាក់ព័ន្ធនានា។<br>សហការ និង ជួយសំរបសម្រួលដល់បណ្តាអង្គការពាក់ព័ន្ធក្នុងការ ជួយផ្នែកសុខភាព អនាម័យ និង ទឹកស្អាត។<br>ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និង បទពិសោធន៍ តាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រង គ្រោះមហន្តរាយស្រុក។<br>តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការនិងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក។ |

| **ក្រុមគ្រប់គ្រងពត៏មាន** | |
|---|---|
| **សមាសភាពអនុប្រធាន** | **តួនាទី និង ការទទួលខុសត្រូវ** |
| ប្រធានការិ.ព័តិមានស្រុក | តាមដានព័តិមាន និង របាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ ផ្សេង ៗ។ |
| ប្រធានការិ. អប់រំ យុវជន និង កីឡា | ផ្សព្វផ្សាយពតិមានព្យាករណ៍ និង ប្រកាសប្រាប់ឱ្យដឹងជាមុនពីគ្រោះទឹកជំនន់ យោងតាមប្រភពពតិមាន ទាំងឡាយដែលទទួលបាន ។ |
| **សមាសភាពសមាជិក :** | ដឹកនាំ និង សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណផលប៉ះពាល់ និងសេចក្តីត្រូវការ ទាំងក្នុងពេល |
| ប្រធានការិ កសិកម្មស្រុក | និងក្រោយពេលគ្រោះទឹកជំនន់ ។ |
| ប្រធានអនុសាខាកាកបាទក្រហម | គ្រប់គ្រង និងទុកដាក់ព័តិមានទាក់ទងនឹងគ្រោះមហន្តរាយ ។ |
| អធិការនគរបាលស្រុក | សហការ និង ជួយសំរបសម្រួលដល់អង្គការនានាក្នុងការវាយទម្លៃ និង ប៉ាន់ប្រមាណប៉ះពាល់ និង សេចក្តីត្រូវការ របស់ជនរងគ្រោះ ។ |
| អនុប្រធានស្រុកប្រតិបត្តិប្រចាំស្រុកស៊ីធរ កណ្តាល | ប្រមូល និង ចងក្រងព័តិមានទាក់ទងនឹងក្រុមអ្នកងាយរងគ្រោះ និង តំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់នានា នៅក្នុងស្រុក ។ |
| មេបញ្ជាការកងអាវុធហត្ថស្រុក | ចូលរួមជាមួយអាជ្ញាធរ ភូមិ ឃុំ និង ក្រុមដទៃ នៅពេលមាន ការស្នើសុំជាក់ស្តែង ។ |
| បញ្ជាការផ្នែកសឹករងស្រុក | ដឹកនាំនិងចូលរួមប្រជុំដើម្បីចែករំលែកព័តិមាននិងបទពិសោធ ដល់ក្រុមប្រតិបត្តិការដទៃ និង អង្គការពាក់ព័ន្ធ នានា។ |
| ប្រធានការិ. អភិវឌ្ឍន៏ជនបទស្រុក | ដឹកនាំការផ្សព្វផ្សាយ និង អប់រំការយល់ដឹងធារណៈដល់ប្រជាពលរដ្ឋ តាមប្រព័ន្ធផ្សព្វផ្សាយដែលមាននៅក្នុងខេត្តទាក់ទងនឹង |
| ១០. ប្រធានការិ.ធម្មការ និង សាសនា ស្រុក | វិធានការកាត់បន្ថយផលប៉ះពាល់ផ្សេង ៗ ដែលបណ្តាលមកពីគ្រោះទឹកជំនន់។ |
| ១១. អង្គការនានា | តួនាទីផ្សេងទៀត នឹងអនុវត្តតាមផែនការនិងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក។ |
| **ក្រុមប្រតិបត្តិការឆ្លើយតបសង្រ្គោះបន្ទាន់** | |
| **សមាសភាពអនុប្រធាន :** | **តួនាទី និង ការទទួលខុសត្រូវ** |
| ប្រធានការិ. កសិកម្មស្រុក | តាមដានព័តិមាន និងរបាយការណ៍ពីស្ថានភាព និង ផលប៉ះពាល់ ផ្សេង ៗ ដោយសារគ្រោះមហន្តរាយនានា។ |
| ប្រធានការិ. សង្គមកិច | ប្រមូលព័តិមាន និង របាយការណ៍ពីអាជ្ញាធរភូមិឃុំ និងក្រុមប្រតិបត្តិការផ្សេង។ ដើម្បីផ្ញើរជូនគណៈកម្មាធិការ គ្រប់គ្រង គ្រោះមហន្តរាយខេត្ត |

| | |
|---|---|
| ប្រធានអនុសាខាកាកបាទក្រហម<br>**សមាសភាពសមាជិក :**<br>បញ្ជាការផ្នែកសឹករងស្រុក<br>បញ្ជាការកងរាជអាវុធហត្ថស្រុក<br>អនុប្រធានស្រុកប្រតិបត្តិប្រចាំស្រុកស៊ីធរ កណ្តាល<br>អធិការសឹករងស្រុក<br>ប្រធានការិ កសិកម្មស្រុក<br>ព្រះអនុគណសង្ឃស្រុក<br>ប្រធានការិ សង្គមកិច្ចស្រុក<br>ប្រធានការិ ផែនការស្រុក<br>អង្គការនានានៅក្នុងស្រុក ។ | ពិនិត្យលទ្ធភាពក្នុងការផ្តល់ជំនួយសង្គ្រោះ ។<br>ដឹកនាំ និង សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីវាយតម្លៃ និង ប៉ាន់ប្រមាណសេចក្តីត្រូវការរបស់ជនរង គ្រោះដើម្បីធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា និង មានប្រសិទ្ធិភាព ។<br>ដឹកនាំប្រតិបត្តិការដទៃ ដើម្បីចុះស្រង់ស្ថិតិប្រជាជនរងគ្រោះនៅ តាមទីសុវត្ថិភាពដើម្បីផ្តល់ជំនួយសង្គ្រោះបន្ទាន់ និង ជ្រើសរើសអ្នកទទួលជំនួយសង្គ្រោះ ដោយមានការចូលរួមពីអាជ្ញាធរភូមិ ឃុំ ។<br>គ្រប់គ្រង ថែរក្សាស្តុកទុក ជំនួយសង្គ្រោះនិងសំភារៈផ្សេងៗទៀត ។<br>ធ្វើការជាមួយក្រុមទទួលខុសត្រូវនៅថ្នាក់ខេត្ត ដោយមានការសហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីបែងចែក និង ដឹកជញ្ជូនជំនួយសង្គ្រោះដល់ប្រជាពលរដ្ឋរងគ្រោះ ។<br>ធ្វើការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និង ខេត្ត ដើម្បីទំនាក់ទំនង និង អំពាវនាវ ដល់ស្ថាប័ន អង្គការ មនុស្សធម៌ សប្បុរសជន និង អង្គការផ្សេងទៀត ដើម្បីស្វែងរកជំនួយ និង ការគាំទ្រ ។<br>សម្របសម្រួល និង ចង្អុលបង្ហាញទីតាំងជនរងគ្រោះដល់បណ្តាអង្គការមនុស្សធម៌ និង សប្បុរសជនដែលគេ មានបំណងចង់ចែកជំនួយសង្គ្រោះដោយខ្លួនគេ ។<br>ធ្វើការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីបន្តការតាមដានស្ថានភាព និងសេចក្តីត្រូវការរបស់ជនរងគ្រោះ ។<br>ដឹកនាំ និង ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍ដល់ក្រុមប្រតិបត្តិការ និង អង្គការ ពាក់ព័ន្ធនានា ។<br>តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការនិងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត ។ |

## ៥. ផែនការសកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់របស់ការិយាល័យ_អង្គភាពជុំវិញស្រុកស៊ីធរកណ្តាល សំរាប់អនុវត្តឆ្នាំ: ២០០៩_២០១១

# លេខាធិការដ្ឋាន
# គណៈកម្មាធិការគ្រប់គ្រង
# គ្រោះមហន្តរាយស្រុក

# ស្រុក ៖ ស៊ីធរកណ្ដាល

**១-ការិយាល័យ/អង្គភាព៖ លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយស្រុក** (អ្នកតំណាង/ជនបង្គោល ៖ **សោម សាម៉ន** ទូរស័ព្ទ៖ ០១២ ១៩០៥ ៧៧២)

| លេខ | ផែនការសកម្មភាពលំអិត | គន្លងវាស់វែង | អ្នកអនុវត្ត និង អង្គភាពពាក់ព័ន្ធ | ធនធានតម្រូវការ និង ថវិកាប៉ាន់ស្មាន | អាទិភាព និង ពេលវេលាអនុវត្ត | | | |
|---|---|---|---|---|---|---|---|---|
| | | | | | ខ្ពស់ | មធ្យម | ទាប | រយៈពេល/ពេល |
| **៥. ការងារត្រៀមបង្ការគ្រោះទឹកជំនន់ (មុនទឹកជំនន់)** | | | | | | | | |
| **៥.១ ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល ដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ឃុំ និង ភូមិ៖** | | | | | | | | |
| *៥.១.១* | រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយដល់សមាជិក សមាជិកា នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ឃុំ ។ | មានចំនួន ៥ វគ្គ= សិក្ខាកាម ១៧៥ នាក់ | - NCDM / PCDM<br>- អង្គភាពជុំវិញស្រុក<br>- អង្គការ ពាក់ព័ន្ធ | - ឯកសារ<br>- អ្នកសំរបសំរួល<br>- ថវិកា ២.០០០ $ | √ | | | មករា-មីនា |
| **៥.២ ការផ្សព្វផ្សាយ និង បង្កើនការយល់ដឹងពីផលប៉ះពាល់ និង វិធានការត្រៀមបង្ការ ឆ្លើយតប ទៅនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ជាពិសេសទឹកជំនន់ ដល់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ងាយរងគ្រោះតាមដងទន្លេមេគង្គ និង ទន្លេនានាក្នុងស្រុក ៖** | | | | | | | | |
| *៥.២.១* | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីការប្រេប្រាស់ប្រព័ន្ធផ្តល់ពតិមានជាមុន អំពីទឹកជំនន់ ។ | ប្រជាពលរដ្ឋចំនួន ២០ ភូមិ ក្នុងតំបន់ ទឹកលិចបានយល់ដឹងអំពីពតិមានទឹកជំនន់ | - មន្ទីរធនធានទឹក និងឧតុនិយម<br>- PCDM | - ឯកសារ<br>- អ្នកសំរបសំរួល<br>- ថវិកា ៤.៥០០ $ | √ | | | មករា-ឧសភា |
| *៥.២.២* | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីការត្រៀមបង្ការ និងការរស់នៅជាមួយទឹកជំនន់ ។ | ប្រជាពលរដ្ឋចំនួន ២០ ភូមិ ក្នុងតំបន់ ទឹកលិចបានយល់ដឹង និងត្រៀមបង្ការ គ្រោះទឹកជំនន់ | - PCDM<br>- អង្គការ ពាក់ព័ន្ធ | - ឯកសារ<br>- អ្នកសំរបសំរួល<br>- ថវិកា ៤.៥០០ $ | √ | | | មករា-ឧសភា |
| **៥.៣ ប្រពន្ធ័ផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ និង ឧបករណ៍វាស់ស្ទង់កំពស់ទឹកជំនន់ដែលបានរៀបចំនៅតាមភូមិ-ឃុំ ជាគោលដៅ ៖** | | | | | | | | |
| *៥.៣.១* | រៀបចំប្រព័ន្ធពតិមាន ឧបករណ៍ បង្គោលវាស់ស្ទង់ទឹកនៅតាមភូមិដែលលិចទឹក ។ | ភូមិចំនួន ១០ ត្រូវបានរៀបចំបំពាក់ក្តារពតិមាន និងបង្គោលស្ទង់ទឹក់ | - មន្ទីរធនធានទឹក និងឧតុនិយម<br>- PCDM និង អង្គការពាក់ពន្ធ័ | - ថវិកា ១០.០០០ $ | √ | | | មករា-ឧសភា |
| **៥.៤ ការស្តុក និងការគ្រប់គ្រងឃ្លាំងស្តុកសំភារៈ និង ជំនួយសង្គ្រោះ៖** | | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **៥.៥ យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរុករកជនរងគ្រោះ ត្រូវបានរៀបចំ និង កំណត់ :** | | | | | | | |
